# ចិត្តមនុស្សក្នុងលោក

## បទបន្ទោលកាក

វេហាស៍ធំឆ្ងាយ　　សត្វហើរប្រញាយជាខ្សែ
ស្រែកយំហូរហែ　　រាល់ខែរាល់ឆ្នាំមិនថ្មី ។
យន្តហោះផ្លោតផ្លោះ　　សន្ធឹកលាន់អស់លោកិយ
មេឃាធ្វើហី　　មិនស្ដីមិនខឹងមនុស្សា ។
ឯដួងចិត្តមនុស្ស　　ចំលែកប្លែកខុសវេហាស៍
គ្មានរូបឡើយណា　　ក្រលាបានសព្វបែបយ៉ាង ។
លោភក្រោធឥច្ឆា　　ប្រាថ្នាជំទើតក្អេងក្អាង
មានះមិនស្វាង　　សំអាងទ្រព្យយសសិទ្ធិ ។
មុខមាត់កិត្តិយស　　អំណាចកេរ្តិ៍ឈ្មោះលាភី
បៀតបៀនយាយី　　ជាន់ឈ្លីល្មើសសិទ្ធិសេរី ។
ខ្លះឃើញអ្នកទាប　　ទុកភាពមិនស្មើដុំដី
ឃើញអ្នកក្រក្រី　　ធ្វើហីមិនខ្ចីចងមិត្ត ។
វក់តែអញឯង　　ជំទែងសំដែងឥទ្ធិឫទ្ធី
កោតតែមិនគិត　　ខំតែប្រឌិតទោសផង ។
ជាតិមនុស្សដូចគ្នា　　ទោះខុសទោះជាម្ចាលម្ដង
រាប់ដូចប្អូនបង　　ក្ដីហ្មងបាត់លែងមានមោះ ។
ឱចិត្តមនុស្សា　　គួរណាតែឈប់ទុយិស
ទោះលើកខ្លួនខ្ពស់　　ក៏មិនផុតហួសម្រឹត្យូវ ។
ចុងក្រោយដូចគ្នា　　ទោះខំពើងពារពេញផ្លូវ
ពេលដាច់ខ្យល់ទៅ　　នឹងត្រូវអស់អ្វីក្អេងក្អាង ។

Ca. ០៧ ឧសភា ២០០៦